រូបភាព ទំព័រ (២៣)

# ១-មនុស្សកើតឆ្នាំជូត

ប្រុសស្រីកើតឆ្នាំជូត នាមកណ្ដុរ សម្ពង្សជាតិទេព្តាប្រុស ធាតុទឹក តាមប្រភពហោរាពោលថា បុគ្គលពួកនេះមាន ចិត្តក្លាហាន ដោយច្រើនអភ័ព្វចំពោះគុណូបការៈដល់គេ ឬធ្វើល្អដល់គេបានផលជាសំណងវិញអាក្រក់ ពាក្យពេចន៍មាន ន័យទូលំទូលាយ ទោះលីលាទៅកាន់ទិសានុទិសមានគេកោតក្រែងស្ញប់ស្ញែង ទទួលរាក់ទាក់ចងមេត្រីភាព តែគង់មានបាប កម្មពីមុនមកនាំឱ្យអ្នកដទៃនិយាយដើម និងកាច់មួយរឿងទទេ ។ ប្រសិនបើបានលាភផលផ្សេង១ លាភនោះច្រើនបរិសុទ្ធ ប្រាសចាកសេចក្ដីចោទប្រកាន់កំហុស ការធ្វើដំណើរទៅណាមកណាមានមិត្តភក្តិចោមរោមយ៉ាងកុះករ ថាបើធ្វើរាជការច បានផលល្អ ដោយមានមិត្តភ្ជាជួយទំនុកបំរុងផ្គុងផ្ដើម កាលណាធ្វើការងារក្នុងមុខតំណែងសឹងបានល្អលើសជាងអ្នកធ្វើការ ក្នុងក្រុម ឬមិត្តភក្ដិដែលធ្វើដូចគ្នា ។ តែច្រើនមានរោគធ្មេញ ក្បាល និងមាត់ សូមថៃធូនឱ្យហ្មត់ចត់នូវអាការៈដូចពេលនេះ ទើបជៀសវាងរោគយាយីបាន ។

.....................................

រូបភាពទំព័រ ២៥

## ២-មនុស្សកើតឆ្នាំឆ្លូវ

ប្រុស-ស្រីកើតឆ្នាំឆ្លូវ នាមគោ ជាតិកំណើតមនុស្សប្រុស ធាតុដី តាមបុព្វបទហោរពោលថាបុគ្គលកំណើតលក្ខណៈ នេះត្រូវតែនិរាសចាកគ្រួគ្រង បើយ៉ាងហោចណាស់ក៏ត្រូវឃ្លាតគ្នាពីខាងដើមការសម្រស់ ។ បើចេញដំណើរទៅរកអ្នកណា រមែងមានសេចក្ដីរីករាយអបអរសាទរពីអ្នកនោះ ព្រមទាំងអ្នកដទៃផង ។ លាភសក្ការៈបានពីពួកចាស់ទុំ អ្នកកាន់ពុទ្ធ សាសនា និងអ្នកឧបត្ថម្ភពីមុនមក ពុំនោះមានអ្នកធំចង្អុលបង្ហាញគំនរលាភ តែជាមនុស្សចូលចិត្តដើរចប្រែបតាមទីនានា ដើរ លឿន ទៅណាមកណាដល់ភ្លាម១ ធ្វើរាជកាពុំបានស្រួលឡើយ សូម្បីជួលឈ្នួលប្រើប្រាស់ក៏មិនស្រួលដែរ ច្រើនមានការ គហារនិន្ទាតែពីអ្នកនៅជាមួយ ដោយអ្នកដទៃចាក់រុកផង ការដែលធ្វើតាមថ្នាក់នាទី ត្រូវបានតែជាមធ្យម បើទុកជាខ្ទះ ខ្ទែងខិតខំប្រតិបត្តិយ៉ាងណាក៏ដោយ ។

អាជីវកម្មគួរដល់បុគ្គលពួកនេះ គឺលក់ដូរគ្រឿងដែក មាស ពេជ្រ ជាងគំនូរ ជាងឈើ ចិញ្ចឹមសត្វកបល្អ ទាំងនេះ ជាអាជីពសម្រាប់គេ ។

.....................................

រូបភាពទំព័រ ២៧

## ៣-មនុស្សកើតឆ្នាំខាល

ប្រុស-ស្រីកើតឆ្នាំខាល នាមដើមខ្លា ជាតិយក្ខស្រី ធាតុឈើ បុព្វបទហោរពោលថា លក្ខណៈរបស់បុគ្គលពួកនេះ កាលវេលាអស់ជីពជន្មច្រើនមិនប្រព្រឹត្តទៅតាមធម្មតា ជាមនុស្សអភ័ព្វក្នុងការទៅរកអ្នកណា រមែងតែងអ្នកនោះធ្វើសោះ អង្កើយគ្មានរីករាយតបវិញ មានបាបកម្មខ្លះនាំឱ្យកើតអាប់អួរហ្មងហ្មង គេច្រើនពោលបញ្ចើចតែនៅចំពោះមុខ កំបាំងមុខគេ

ពេបជ្រាយនិយាយដើម ច្រើនបានលាភសក្ការៈច្រើនពណ៌ស និងលឿង លើសលាភសក្ការៈទាំងពួង ថាបើចរទៅកាន់ទីឆ្ងាយរមែងមានរមែងមានប៉ះទង្គិចមុតកោសជារបួសញយៗ ពុំនោះមានឈឺជាប់ដោយឡែកទៀត ចូលខ្លួនធ្វើផ្គាប់ផ្គុនធ្វើ ជាខ្ញុំរាជការរមែងបានទទួលសេចក្ដីអនគ្រោះពីចៅហ្វាយនាយ ពីអ្នកមានសម្បត្តិ ធ្វើរាជការកាន់មុខតំណែងបានប្រសើរ តោងស្និទ្ធស្នាលជិតជិតនឹងមនុស្សសំបុរស ទើបជួយយិតយោងឱ្យចំរើនយស-អំណាច ។

អាជីវកម្មគួរដល់បុគ្គលពួកនេះ ការបោកអ៊ុត គូរវាស ឆ្លាក់ជារូបផ្សេងៗ លក់ដូររបស់រឹងៗ ទាំងអស់នេះជារបស់សមគួរដល់គេ ។

..............................................

## រូបភាពទំព័រ (២៩)

## ៤-មនុស្សកើតឆ្នាំថោះ

ប្រុស-ស្រីកើតឆ្នាំថោះ នាមដើមទន្សាយ ជាតិមនុស្សស្រី ធាតុឈើ តាមបុព្វបទហោរពោលថា លក្ខណៈរបស់បុគ្គលពួកនេះកាលដល់ថ្នាក់ជរាកម្មបរិភោគរបស់ខុសទំនងបណ្ដាលឱ្យអស់ជន្មាយុ ចរទៅកាន់ទិសានុទិសនានាតែងតែបានគេទាំងឡាយរាប់រកយកជាមេត្រី ដូចជាសាច់សន្តានរួមលោហិត និស្ស័យជាប់មកពីជាតិមុនបណ្ដាលឱ្យមានអធ្យាស្រ័យ ទន់ភ្លន់ចេះត្រសោះអន្ទងមនុស្សឱ្យលុះក្នុងគតិល្អ បានតាមគន្លងរបស់បណ្ឌិតអ្នកប្រាជ្ញ តែលាភសក្ការៈដូចជាមាស ប្រាក់ជាដើមច្រើនបានមកដោយទុក្ខលំបាកជាមុន ឬបានហើយទើបមានសេចក្ដីក្ដៅក្រហាយជាខាងក្រោយ កិរិយាដើរទៅណាមកណាលឿន ហើយមិនចេះដំអក់ឡើយ ប៉ុន្តែទៅណាម្នាក់ឯងមិនបានផលល្អសោះ បើចូលខ្លួនបំរើរាជការនាហ្នឹនគហបតីរមែងមានពួកស្រីៗចោមរោម និងទំនុកបំរុង កាលណាបានកាន់តំណែងកិច្ចការរាជការច្រើនមានការចាក់រុកពីអ្នកធ្វើការ រួម ឬអ្នកទន់ខ្សោយជាងខ្លួន ច្រើនឥច្ឆាឈ្នានីស ។

.........................................

## រូបភាពទំព័រ (៣១)

## ៥-មនុស្សកើតឆ្នាំរោង

ប្រុស-ស្រីកើតឆ្នាំរោង នាមដើមពស់នាគរាជ ជាតិទេព្តាប្រុស ធាតុមាស តាមបុព្វបទហោរពោលថា បុគ្គលពួកនេះមានលក្ខណៈជាមនុស្សរងគ្រោះដល់ជីវិត ដោយយកអាសារអ្នកធំ ទោះនៅទីកន្លែងណាមានគេជួយឈឺឆ្អាល យកអាសារដូចបងប្អូននឹងគ្នា មានកម្មពៀរខ្លះនាំឱ្យមុតប៉ះទង្គិចជារបួសព្រោះអ្នកដទៃ លាភសក្ការៈតិចច្រើនបានដោយសារស្ត្រី ផ្ដល់ ឬណែនាំចង្អុលប្រាប់ នោះចរចេញដំណើរច្រើនយឺតយ៉ាវ ហើយចំអៀកកិចកុងក៏ច្រើនផង ពុំនោះច្រើនយកកិច្ចកលមកបង្ហាក់ដំណើរការ ចូលបម្រើអ្នកធំឬអ្នកមានសម្បត្តិ គប្បីធ្វើការឱ្យត្រឹមស្មើ តែកម្លាំងសមត្ថភាពខ្លួន បើធ្វើឱ្យជាង នេះទៅទៀតផលការព្រមទាំងសេរីភាពខ្លួនក៏មុខជាត្រូវគេទម្លាក់ដាក់កំហុសមកលើជាមិនខាន បើធ្វើជាខ្ញុំរាជការ កាន់នាទីតំណែងទទួលខុសត្រូវផ្ទាល់ខ្លួនបានល្អណាស់ មានអំណាចច្រើន បានទទួលកេរ្តិ៍ឈ្មោះសាយសុះសព្វទីកន្លែងយ៉ាងស្ងប់ ស្វែងជាពិសេសអ្នកក្រោមបញ្ជាគោរពមិនមានឆ្គង ។

.....................................

រូបភាពទំព័រ (៣៣)

## ៦-មនុស្សកើតឆ្នាំម្សាញ់

ប្រុស-ស្រីកើតឆ្នាំម្សាញ់ នាមដើមពស់វែក ជាតិមនុស្សប្រុស ធាតុឈើ តាមបុព្វបទហោរពោលថា បុគ្គលពួកនេះមានលក្ខណៈជាមនុស្សរងទារុណកម្មក៏ព្រោះតែយកអាសារនាយ ឬអ្នកធំ ពុំនោះមានសេចក្ដីនឿយលំបាកលើសកម្លាំងដែលអាចនឹងប្រព្រឹត្តទៅតាមធម្មតា ជាមនុស្សអភ័ព្វក្នុងការទៅរកគេ ដោយគេមិនសូវអើពើ ឬ មិនរីករាយរាប់រកដោយស្មោះអស់ពីពោះ មានវេរាកម្មខ្លះអាចឱ្យគិតខុស គឺភ្លេចខ្លួនខំធ្វើល្អដល់គេ ហើយគេគ្មានសារភាពឬផ្ដល់អ្វីតបវិញ ជាការ លើកទឹកចិត្ត បើបានលាភសក្ការៈក៏ដោយសារស្រីមានវ័យក្មេង បើម្ចាស់ជាតាភេទស្រី ត្រូវបានលាភសក្ការៈពីមនុស្សប្រុស ចាស់វ័យ នៅក្នុងទីកន្លែងស្ដីនិយាយតិច លុះចេញទៅកាន់ទីស្ថាននានា បញ្ចេញវេហាស្ទើរតែមិនបង្អង់មាត់ ចូលបំរើការ នាយ ឬ នាហ្មឺនមន្ត្រីគហបតី គប្បីធ្វើការត្រឹមតែមធ្យម ទើបបានស្ថេរភាពគ្មានផលអាក្រក់ កាលណាបានកាន់មុខតំណែង ការរាជការមិនសូវបានជាទីសរសើរអំពីសំណាក់អ្នកធ្វើការរួម ឬ នាយចៅហ្វាយផ្ទាល់ ។

.....................................

រូបភាពទំព័រ (៣៥)

## ៧-មនុស្សកើតឆ្នាំមមី

ប្រុស-ស្រីកើតឆ្នាំមមី នាដើមសេះ ជាតិទេពកញ្ញា ធាតុភ្លើង តាមបុព្វបទហោរពោលថា បុគ្គលពួកនេះមានលក្ខណៈជាមនុស្ស ដល់ពេលជរាកម្មនិងមរណៈដោយរឿងទ្រព្យប្រាក់មាស និងពេជ្រ បើចេញដំណើរទៅរកគេ គេនឹងរាប់អានស្និទ្ធស្នាលដូចបងប្អូនបង្កើត បើសំបូរទ្រព្យធនប្រាក់មាសជាដើម ច្រើនទុកចិត្តគេណាស់ វេរាកម្មខ្លះបណ្ដាលឱ្យមានចិត្តលោភលន់ ឬពុតត្បុតផ្សេងៗ ព្រោះតណ្ហា លាភសក្ការៈទាំងពួងដែលត្រូវកើតមាន ទោះជាប្រការណាក៏ដោយ ច្រើនតែ មានដំណឹងពីមជ្ឈដ្ឋានដឹងការណ៍ច្បាស់ ថាបើធ្វើដំណើរទៅណាមកណាចូលចិត្តតែដើរក្រោយគេ ឬប្រចាំជើង ។ ខ្លួនមកបំរើការនាយចៅហ្វាយ នាហ្មឺនមន្ត្រី អ្នកមានសម្បត្តិរមែងបានល្អប្រសើរ ដោយបណ្ឌិតអ្នកប្រាជ្ញជួយដាស់តឿនរំឭក រឿយៗ កាលណាបានកាន់តំណែងការងាររាជការគ្រប់គ្រងក្រសួងច្រើនបានជាធំ ហើយជួយអ្នកដទៃបានទទួលសេចក្ដីរីករាយសំបូរសប្បាយផងដែរ ។

...........................................

រូបភាពទំព័រ (៣៧)

## ៨-មនុស្សកើតឆ្នាំមមែ

ប្រុស-ស្រីកើតឆ្នាំមមែ នាដើមពពែ ជាតិទេពធីតា ធាតុមាស តាមបុព្វបទហោរពោលថា បុគ្គលពួកនេះមានលក្ខណៈជាមនុស្សអភ័ព្វ ចិត្តក្លាហាន ពាក្យពេចន៍ពិរោះពិសារ ទោះទៅកាន់ទីដៅនានាមានគេយកចិត្តទុកដាក់ដោយកោត ក្រែងចេះមានគំនិតនិងសំដីព្រមស្ទើនឹងភាពខ្លួនមានវេរាកម្មខ្លះ បណ្ដាលឱ្យចង់តែនិយាយកើ្តពីអ្នកដទៃ ទោះបីក្ដី មិនពិត ក្ដី ចូលចិត្តនាំពីឯណេះទៅប្រាប់ឯណោះ នាំមកពីខាងណោះមកប្រាប់ខាងណេះ លាភសក្ការៈច្រើនបានដោយសារអ្នកដទៃជួយដឹកនាំប្រាប់ទំនង បើចេញដំណើរទៅកាន់ទិសនានាច្រើនមានគេចោមរោមជុំវិញជាក្រុមជាហ្វូងដោយរីករាយ ធ្វើរាជ

ការបានធំដោយបុណ្យសក្តិ មានមិត្តភក្តិជួយយិតយោង មិត្តនោះច្រើននៅឃ្លាតឆ្ងាយពីគ្នា កាលណាកាន់មុខតំណែងទទួលខុសត្រូវផ្ទាល់ខ្លួន ច្រើនមានអធ្យាស្រ័យសន្តោសដល់អ្នកក្រោមបញ្ជា ឬអន់ទន់ខ្សោយទូទៅ ជាពិសេសនឹងបានរុងរឿងលើសមិត្តភក្តិស្របាលគ្នាចេញធ្វើការ ។

.........................................

## រូបភាពទំព័រ (៣៩)

## ៩-មនុស្សកើតឆ្នាំវក

ប្រុស-ស្រីកើតឆ្នាំវក នាមដើមស្វា ជាតិយក្សប្រុស ធាតុដែក តាមបុព្វបទហោរពោលថា បុគ្គលនេះមានលក្ខណៈជាមនុស្សច្រើនតែនិរាសឃ្លាតចាកគូសម្រស់របស់ខ្លួន ឬក៏ថាមានគូច្រើន បើចេញដំណើរទៅកាន់ទីស្ថាននានា រមែងមានគេរង់ចាំដំណើរទទួលអបអរសាទរធ្វើការបដិសណ្ឋារកិច្ចយ៉ាងជិតស្និទ្ធ មានបុព្វកម្មពីជាតិមុនខ្លះបណ្តាលឱ្យនឹកចង់តែនិយាយលើកដាក់បំផ្លើសការណ៍ពិតពីអ្នកដទៃ លាភសក្ការៈច្រើនបានពីពួកអ្នកប្រកាន់សាសន៍ ពណិសំបុរ និងចាស់ទុំ ព្រឹទ្ធាចារ្យទូទៅ ឬអ្នកធំអាចចង្អុលបង្ហាញហេតុផលឱ្យរឿយៗ ។ ថាបើមានដំណើរទៅណាមកណា ច្រើនដើរលឿន ធ្វើដំណើរ រហ័សតែច្រើនរពឹសដៃជើងបន្តិច ធ្វើរាជការមិនសូវសំខាន់ទេ ដោយហេតុថាមានចរិយារបិុលរប៉ូចខិលខូចផ្សំផង មិន គ្រាន់ តែយ៉ាងនេះទេ បើជាចូលខ្លួនបំរើផលប្រយោជន៍អ្នកធំ ឬអ្នកមានសម្បត្តិក៏ឆាប់ខុសឆាប់ត្រូវដែរ កាលណាបានកាន់កាប់មុខតំណែងការក៏បានត្រឹមតែមធ្យម ប្រសិនបើខ្ពស់ជាងនេះទៀតក៏នឹងបានទទួលអាប់កិត្តិយស ធ្លាក់អំណាចភ្លាមមួយរំពេច ។

....................................

## រូបភាពទំព័រ (៤១)

## ១០-មនុស្សកើតឆ្នាំរកា

ប្រុស-ស្រីកើតឆ្នាំរកា នាមដើមមាន់ចែ ជាតិយក្សប្រុស ធាតុដែក តាមបុព្វបទហោរពោលថា បុគ្គលពួកនេះមានលក្ខណៈជាមនុស្ស ដល់ថ្នាក់ជរាកម្មជីពជន្មមិនប្រក្រតី ថាបើទៅណាមកណាច្រើនគេធុញថប់មិនរោះរាយតប ជាមនុស្សអភ័ព្វក្នុងរឿង នេះបុព្វកម្មពីមុនមកបណ្តាលឱ្យគេកោតសរសើរតែនៅចំពោះមុខ លុះកំបាំងមុខ គេនិយាយអាក្រក់ពីខ្លួន ផ្សេងៗ លាភលឿង លាភស បុគ្គលពួកនេះច្រើនបានញឹកញាប់ជាងលោភសក្ការៈទាំងពួង ការធ្វើដំណើរទៅកាន់ទិសទី នានាច្រើនមានប៉ះពារជល់ទង្គិច ជាហេតុឱ្យមានរបួសស្នាម ជាំដាមមិនលែង ចូលខ្លួនបំរើផលប្រយោជន៍ចៅហ្វាយនាយ នាហ្មឺន មន្ត្រីគហបតីបានជាទីគាប់ចិត្ត ជឿស្តាប់អស់លោកទាំងនោះ បើធ្វើរាជការកាន់មុខតំណែងទទួលខុសត្រូវផ្ទាល់បាន ល្អដោយអ្នកទទួលបញ្ជាទូទៅមានភក្តីភាព គោរពសព្វប្រការ ជាពិសេសការដែលបានធ្វើនោះមានសភាពយ៉ាងណាក៏ ដោយ ។

.............................................

រូបភាពទំព័រ (៤៣)

## ១១-មនុស្សកើតឆ្នាំច

ប្រុស-ស្រីកើតឆ្នាំច នាមដើមឆ្កែ ជាតិយក្សស្រី ធាតុដី តាមបុព្វបទហោរពោលថា បុគ្គលពួកនេះមានលក្ខណៈជា មនុស្សអស់ជន្មាយុព្រោះបរិភោគវត្ថុវត្ថុមានរសជាតិខុសធម្មតា បើមានការទៅកាន់ទីស្ថាននានាច្រើនមានគេរីករាយ សាទរទទួលយកធ្វើជាមិត្តមេត្រី ជួយឈឺឆ្អាលយកអាសារតាមការមាន ការបាន បុព្វកម្មជាប់តាមមកពីជាតិមុនខ្លះ បណ្តាលឱ្យយល់ឱ្យស្គាល់ចរិយាដំណើររបស់អ្នកប្រាជ្ញរាជបណ្ឌិតនិងមនុស្សទូទៅ លាភសក្ការៈទាំងពួងដូចជាប្រាក់ មាស ជាដើម ថាបើបានមកច្រើនមានសេចក្តីនឿយលំបាកជាមុន ក្តៅក្រហាយសិនពុំនោះខាងដើមសុខស្រួលទេ តែដល់បានលាភនោះមកក៏បែរជាមានការពុំស្រួលខាងក្រោយក៏មាន ជាមនុស្សដំណើររហ័សរហួន ទៅណាមកណាឆាប់ត្រឡប់ បើចូលខ្លួនបំរើផលប្រយោជន៍អ្នកធំបានស្រីជួយទំនុកបំរុងផ្តល់សេចក្តីសុខឱ្យ កាលណាបានកាន់កាប់មុខតំណែងការ ច្រើនមានអ្នកចាំប្រទូស្តរាយបុករុកជានិច្ច ។

រូបភាពទំព័រ (៤៥)

## ១២-មនុស្សកើតឆ្នាំកុរ

ប្រុស-ស្រីកើតឆ្នាំកុរ នាមដើមជ្រូក ជាតិមនុស្សស្រី ធាតុទឹក តាមបុព្វបទហោរពោលថា បុគ្គលពួកនេះមានលក្ខណៈជាមនុស្សត្រូវរងជីវិតដោយការយកអាសារ ឈឺឆ្អាលនាយ អ្នកធំ បើមានកិច្ចការទៅកាន់ទិសទីនានា មានគេចោមរោមស្រឡាញ់រាប់អានទុកដូចជាបងប្អូននិងគ្នា បុព្វកម្មជាប់ជិតដាមមកពីជាតិមុនបណ្តាលឱ្យមានរបួសជាដំណាំ(គួរប្រយ័ត្ន)ព្រោះការប្រឹងប្រលែងលេង លាភសក្កាៈទាំងពួងបើនឹងបានដោយច្រើនៗ បានដោយសារស្រីផ្តល់ឱ្យ ឬជួយទំនុកបំរុងរឿយៗ ជាមនុស្សដំណើរយឺតយ៉ាវ ចំអៀកទ្រមក់បន្តិច បើចូលខ្លួនបំរើការផ្ទាល់នាហ្មឺន គហបតី គួរធ្វើឱ្យល្មមសម មាឌកុំបង្ខំឱ្យហួសសមត្ថភាព ព្រោះថាកាលណាបង្ខំ ឬធ្វើដោយប្រឹងហួសពេកនឹងក្លាយទៅជាធ្លាក់ចិត្តអស់សង្ឃឹមខូច គំនិតទទេៗ ធ្វើរាជការមានស្នាដៃ ប្រកបទៅដោយកិត្តិយសល្បីសាយ ព្រោះសេចក្តីស្លូតត្រង់របស់ខ្លួន ។

.

..........................................